**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

# កិច្ចព្រមព្រៀង
## រវាង
## សហជីពកម្មករនិយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ
## និង
## ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ

កិច្ចព្រមព្រៀងនេះត្រូវបានធ្វើឡើងនៅថ្ងៃ ទី២៧ ខែសីហា ឆ្នាំ២០២១ រវាងសហជីពកម្មករ និយោជិតសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ (ពីនេះតទៅហៅថា"សហជីព") និង ក្រុមហ៊ុនសណ្ឋាគាររ៉ាហ្វិលហ្គ្រែនឌឺអង្គរ (ពីនេះតទៅហៅថា "និយោជក")។ ភាគីនីមួយៗអាចហៅដោយឡែកថា "ភាគី" និងហៅជារួមថា "គូភាគី"។

សណ្ឋាគារ Raffles Grand Hotel d'Angkor កំពុងប្រឈមនឹងការលំបាកផ្នែកសេដ្ឋកិច្ចក្នុងកំឡុងពេលនៃជំងឺរាតត្បាតជាសកល COVID-19 ដែលមិនធ្លាប់មានពីមុនមក។ ការផ្ទុះឡើងនៃជំងឺកូវីដណាវីរុសទូទាំងពិភពលោកបានបណ្តាលឱ្យ សណ្ឋាគារត្រូវបង្ខំចិត្តផ្អាកប្រតិបត្តិការរបស់ខ្លួន។ ដូច្នេះ និយោជក និងសហជីព បានធ្វើការចរចា និងព្រមព្រៀងលើការព្យួរកិច្ចសន្យាការងារកម្មករនិយោជិតចំនួន ១២៣នាក់ (ស្រី៣៦នាក់) ក្នុងចំណោមកម្មករនិយោជិតសរុបចំនួន ២១២នាក់ (ស្រី ៧៤នាក់) រយៈពេល ៣០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី១ ខែកញ្ញា ឆ្នាំ២០២១ រហូតដល់ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០២១។

គូភាគីទាំងពីរព្រមព្រៀងគ្នាទទួលយកលក្ខខណ្ឌដូចខាងក្រោម៖

និយោជិតដែលត្រូវបានព្យួរការងារជាបណ្តោះអាសន្ននឹងទទួលបានអត្ថប្រយោជន៍ដូចខាងក្រោម៖

- ១៥% នៃប្រាក់ខែគោលប្រចាំខែ សម្រាប់ប្រធានផ្នែក អនុប្រធានផ្នែក ប្រធានក្រុម និង អនុប្រធានក្រុម ដែលមានប្រាក់ខែច្រើនជាង ១,០០០ ដុល្លារអាមេរិក។
- ២០% នៃប្រាក់ខែគោលប្រចាំខែ សម្រាប់និយោជិតដែលមានប្រាក់ខែតិចជាង ១,០០០ ដុល្លារអាមេរិក ហើយចំនួនប្រាក់ខែអប្បបរិមាដែលទទួលបានគឺ ៦០ ដុល្លារអាមេរិកក្នុងមួយខែក្នុងអំឡុងពេលនៃការព្យួរការងារ។
- និយោជិតនឹងទទួលបាន**អង្ករ ១០ គីឡូក្រាម និង ត្រីខ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់ក្នុងអនុសញ្ញារួមនឹងបន្តអនុវត្តដ៏ដែលក្នុងកំឡុងការព្យួរការងារ។
- អតីតភាពការងារនឹងមិនទទួលរងផលប៉ះពាល់។ ក្នុងករណីពិសេសដែលសណ្ឋាគារតម្រូវឲ្យនិយោជិតមកធ្វើការ សណ្ឋាគារនឹងផ្តល់ប្រាក់ឈ្នួល ១០ ដុល្លារអាមេរិកក្នុងមួយថ្ងៃ (៨ ម៉ោង) កំឡុងការព្យួរការងារនេះ។

សណ្ឋាគារនឹងតម្រូវឱ្យនិយោជិតមួយចំនួនបន្តធ្វើការពេញម៉ោងក្នុងអំឡុងពេលនៃការផ្អាកប្រតិបត្តិការនេះដើម្បីថែទាំសណ្ឋាគារ។

- និយោជិតទាំងនេះនឹងទទួលបានប្រាក់ឈ្នួល ១០០% និង ប្រាក់ឧបត្ថម្ភធ្វើដំណើរបន្ថែមចំនួន **៣០ ដុល្លារ** ក្នុងមួយខែ។
- រាល់អត្ថប្រយោជន៍ដែលមានស្រាប់នៅរក្សាដូចធម្មតា ។
- និយោជិតដែលបំពេញភារកិច្ចនឹងទទួលបានអាហារជាធម្មតា។

Raffles Grand Hotel
Pte., Ltd.

- និយោជិតទាំងនេះអាចនឹងត្រូវបានស្នើសុំឱ្យបំពេញការងារក្រៅកាតព្វកិច្ចធម្មតារបស់ខ្លួន។ ប៉ុន្តែ ការបណ្តុះបណ្តាលដែលសមរម្យនឹងត្រូវបានផ្តល់ដើម្បីធានាថាកិច្ចការអាចត្រូវបានបញ្ចប់ដោយសុវត្ថិភាព (ឧទាហរណ៍៖ បុគ្គលិកផ្នែកម្ហូបអាហារនិងភេសជ្ជៈធ្វើការសំអាតអាងទឹក)។ ក្នុងករណីមានការកក់សណ្ឋាគារជាក្រុមភ្លាមៗក្នុងកំឡុងពេលផ្អាក

សូមបញ្ជាក់ថាកិច្ចព្រមព្រៀងនេះនឹងចាប់ផ្តើមនៅថ្ងៃទី ១ ខែកញ្ញាឆ្នាំ ២០២១ រហូតដល់មានការជូនដំណឹងបន្ថែម។ នៅពេលស្ថានការណ៍កូវីដ -១៩ មានភាពប្រសើរឡើង ហើយយើងមានភាពច្បាស់លាស់អំពីកាលបរិច្ឆេទបើកសណ្ឋាគារឡើងវិញ និយោជកនឹងពិនិត្យឡើងវិញនូវគ្រោងការណ៍ប្រាក់ឈ្នួលទាំងនេះ។

គូភាគីព្រមព្រៀងលើកិច្ចព្រមព្រៀងនេះដោយចុះហត្ថលេខាខាងក្រោមនេះ៖

ចុះហត្ថលេខាតាងនាមភាគីនិយោជក

សៀមរាប ថ្ងៃទី.២៤ ខែ .សីហា.... ឆ្នាំ២០២១
ហត្ថលេខា និងត្រា
នាយកសណ្ឋាគារ

ព្រះរាជាណាចក្រកម្ពុជា
រ៉េហ្វល ក្រេន អូតែល
Raffles Grand Hotel Pte., Ltd.
ខេត្តសៀមរាប

Dennis de Groot

ចុះហត្ថលេខាតាងនាមភាគីសហជីព

រស់ ប៊ុនណាល់
ប្រធានសហជីព

វើង ភីរុធ
អនុប្រធានសហជីព

មៅ វណ្ណដា
លេខាធិការសហជីព

ប៉ាត សំបូរ
ប្រធានកិត្តិយសសហជីព